**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៦៩១ ព.ណ..គ.ទ

ថ្ងៃព្រហស្បតិ៍ ៧កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសប្រតិបត្តិករនៅស្ថានីយ៍ចំណតរថយន្តមិត្តភាព កម្ពុជា-ជប៉ុន ខេត្តកំពង់ឆ្នាំង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនសាធារណជន នីតិបុគ្គល និងក្រុមហ៊ុនទាំងអស់មេត្តាជ្រាបថា៖ ក្រោមមូលនិធិសមាហរណកម្មអាស៊ាន-ជប៉ុន ក្រសួងពាណិជ្ជកម្ម សហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICS) បានបញ្ចប់ការសាងសង់ស្ថានីយ៍ចំណតរថយន្តមិត្តភាព កម្ពុជា-ជប៉ុន ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ នេះ។ អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្ម សម្រេចធ្វើការជ្រើសរើសប្រតិបត្តិករដើម្បីដំណើរការស្ថានីយ៍ចំណតនេះដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១. ជាក្រុមហ៊ុនស្របច្បាប់ដែលបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្ម បានអនុវត្តកាតព្វកិច្ចនានាតាមការតម្រូវដោយបញ្ញត្តិច្បាប់ និងកាតព្វកិច្ចពន្ធដារត្រឹមត្រូវ
២. មានផែនការអាជីវកម្មនៅស្ថានីយ៍ចំណតរថយន្តច្បាស់លាស់
៣. មានបទពិសោធន៍គ្រប់គ្រង និងដំណើរការស្ថានីយ៍ចំណតរថយន្តដែលមានលក្ខណៈស្តង់ដារជាតិ ឬអន្តរជាតិ យ៉ាងតិច ០៣ឆ្នាំ
៤. មានធនធានខ្ពស់ក្នុងការគ្រប់គ្រង និងដំណើរការស្ថានីយ៍ចំណត សម្រាប់បម្រើជូនអ្នកធ្វើដំណើរទូទៅ
៥. ជាក្រុមហ៊ុនទេសចរណ៍ ក្រុមហ៊ុនដឹកអ្នកដំណើរ ឬក្រុមហ៊ុនដែលមានជំនាញគ្រប់គ្រង ឬ ទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុននានា ដូចជាក្រុមហ៊ុនទេសចរណ៍ ឬក្រុមហ៊ុនដឹកអ្នកដំណើរ ។
៦. មានកិច្ចសហការ អនុញ្ញាត និងជួយសម្រួលឲ្យមានការរៀបចំផ្សព្វផ្សាយ ឬជំរុញការលក់ផលិតផលដែលផលិតក្នុងខេត្ត ក្នុងតំបន់ ឬក្នុងប្រទេសកម្ពុជា។

ក្រសួងពាណិជ្ជកម្ម នឹងរៀបចំកម្មវិធីធ្វើទស្សនកិច្ចទីតាំងស្ថានីយ៍ចំណតរថយន្តផ្ទាល់ និងមានការធ្វើបទបង្ហាញសង្ខេប ស្តីពីគោលបំណងក្នុងការសាងសង់ស្ថានីយ៍ចំណតនេះ នៅថ្ងៃចន្ទ ១២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ សម្រាប់ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ និងបានដាក់ពាក្យមកក្រសួងពាណិជ្ជកម្ម។

ក្រសួងពាណិជ្ជកម្ម នឹងចាប់ផ្តល់និងទទួលពាក្យស្នើសុំចាប់ពីថ្ងៃធ្វើទស្សនកិច្ចទីតាំងស្ថានីយ៍ចំណត រហូតដល់ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១៨។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន នីតិបុគ្គល និងក្រុមហ៊ុនទាំងអស់ដែលមានចំណាប់អារម្មណ៍ ធ្វើជាប្រតិបត្តិករស្ថានីយ៍ចំណតរថយន្តមិត្តភាព កម្ពុជា-ជប៉ុន ខេត្តកំពង់ឆ្នាំង ធ្វើការទាក់ទងតាមលេខទូរស័ព្ទ៖ លោក កៅ សត្ថា ០១៥ ៥៣៧ ៥៣៨ និងលោក ជា ចាន់នីណា ០៩២ ៨៥៥ ៥២៤ ។

**សូមអរគុណ**

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469